**ស្ថានទូតអូស្ត្រាលី**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

<u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣

# ពិធីសម្ពោធកម្មវិធីពន្លកចំណេះ ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា - ដំណាក់កាលទី២

ថ្ងៃនេះ ស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា និងអង្គការមូលនិធិអាស៊ី បានសម្ពោធកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា។

កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជាដំណាក់កាលទី ២ (ឆ្នាំ២០២៣-២០២៧) មានគោលបំណងគាំទ្រដល់ដំណើរការតាក់តែងគោលនយោបាយសាធារណៈ តាមរយៈការធ្វើសេចក្តីសម្រេចគោលនយោបាយដោយផ្អែកលើភស្តុតាង និងកិច្ចពិភាក្សាប្រកបដោយបរិយាបន្ន។ នេះជាដំណាក់កាលទី២នៃកម្មវិធី ដែលបានកសាងសមត្ថភាពរបស់ស្ថាប័នស្រាវជ្រាវនៅប្រទេសកម្ពុជា ក្នុងការធ្វើការស្រាវជ្រាវប្រកបដោយគុណភាព និងរួមចំណែកក្នុងការផ្តល់អនុសាសន៍ផ្នែកគោលនយោបាយ។

ក្នុងពិធីសម្ពោធកម្មវិធីនេះ ក៏មានការចូលរួមពីតំណាងមកពីខាងស្ថាប័នរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ វិទ្យាស្ថានស្រាវជ្រាវ ស្ថាប័នអប់រំ និងអង្គការសង្គមស៊ីវិលនានា ។

ឯកឧត្តម ចាស្ទីន វ៉ាយអេត ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅកម្ពុជា បានមានប្រសាសន៍ថា "អូស្ត្រាលីមានមោទនភាពដែលបានធ្វើជាដៃគូជាមួយស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។ កម្មវិធីពន្លកចំណេះ នឹងជួយគាំទ្រដល់យុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងរយៈពេល ៥ ឆ្នាំខាងមុខនេះ តាមរយៈការរៀបចំគោលនយោបាយដោយផ្អែកលើទិន្នន័យ" ។

លោកស្រី Meloney Lindberg តំណាងអង្គការមូលនិធិអាស៊ីប្រចាំនៅកម្ពុជា បានមានប្រសាសន៍ថា "កម្ម-វិធីពន្លកចំណេះ នៅក្នុងដំណាក់កាលទី២នេះ មានគោលបំណងឆ្លើយតបនឹងឱកាសដែលកំពុងមាននៅក្នុងប្រទេសកម្ពុជា ដូចជាការពង្រឹងវេទិកាសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន និងការរួមចំណែកក្នុងការបង្កើនភស្តុតាងសម្រាប់រៀបចំគោលនយោបាយប្រកបដោយបរិយាបន្ន និងតម្រូវការចំណេះដឹងពីប្រភពមូលដ្ឋាន។ កម្មវិធីនេះនឹងចូលរួមកសាងទំនុកចិត្ត តួអង្គគោលនយោបាយមកពីគ្រប់ស្ថាប័ន ក្នុងដំណើរការរៀបចំគោលនយោបាយ រួមមាន ស្ថាប័នរដ្ឋាភិបាល វិទ្យាស្ថានស្រាវជ្រាវ ស្ថាប័នអប់រំ អ្នក-ជំនាញស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋានជាដើម"។

នៅដំណាក់កាលទី២របស់កម្មវិធីនេះ ក៏នឹងផ្តល់ឱកាសថ្មីដល់អង្គការសង្គមស៊ីវិល និងស្ថាប័នស្រាវជ្រាវដែលកំពុងស្វែងរកមូលនិធិសម្រាប់គាំទ្រដល់ការស្រាវជ្រាវផងដែរ។ ស្ថាប័នស្រាវជ្រាវ និងអង្គការសង្គម-ស៊ីវិលនានា អាចដាក់ពាក្យស្នើសុំមូលនិធិស្រាវជ្រាវ (Innovative Fund) សម្រាប់គាំទ្រការស្រាវជ្រាវប្រកបដោយបរិយាបន្ន និង ការពិភាក្សាពីគោលនយោបាយនៅកម្ពុជា។ រាល់ព័ត៌មានលម្អិត និងដំណើរ-ការដាក់ពាក្យស្នើសុំ អាចស្វែងរកបាននៅលើគេហទំព័រពន្លកចំណេះនៅ www.policypulse.org ។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au